# ចម្លាក់ព្រះវិស្ណុផ្ទុំនៅសម័យមុនអង្គរ

នៅសម័យបុរាណឥទ្ធិពលសាសនាធំៗចំនួនពីរ បានចាក់ឫសយ៉ាងរឹងមាំនៅក្នុងសង្គមខ្មែរ។ ក្នុងនោះឥទ្ធិពលព្រហ្មញ្ញសាសនាខ្មែរ បានគោរពយ៉ាងហ្មត់ចត់ដូចឥណ្ឌាដែលជាម្ចាស់អញ្ចឹង។ រឿងរ៉ាវទេវកថាជាច្រើនដែលមាននៅក្នុងគម្ពីរ ខ្មែរបានឆ្លាក់ជាចម្លាក់នៅលើថ្មឡើងត្រាប់តាមគម្ពីរទាំងនោះ។ នៅក្នុងអត្ថបទខ្លីនេះ ខ្ញុំសូមលើកយកអំពីចម្លាក់ព្រះវិស្ណុផ្ទុំនៅសម័យមុនអង្គរ ពោល គឺលើកយកតែចម្លាក់នៅស.វ.ទី៧ មកបរិយាយខ្លីតែប៉ុណ្ណោះ។ កាលពីឆ្នាំ១៩៦៥ លោកស្រី Mireille Bénisti ជាប្រវត្តិសិល្បៈវិទូធ្លាប់បានសិក្សាអំពីចម្លាក់ព្រះវិស្ណុផ្ទុំនៅក្នុងសិល្បៈខ្មែរទាំងសម័យមុនអង្គរ និងសម័យអង្គរ។[១] ក្នុងនោះលោកស្រីបានរៀបរាប់អំពីផ្តែរទ្វារមានចម្លាក់ព្រះវិស្ណុផ្ទុំសម័យមុនអង្គរចំនួន៥ផ្ទាំង រួមមានផ្តែរប្រាសាទបាសែត (បាត់ដំបង), ផ្តែរទួលអង្គ (កំពង់ស្ពឺ), ផ្តែរគុកព្រះធាតុ (ហាន់ជ័យ), ផ្តែរប្រាសាទស្រីគ្រប់ល័ក្ខណ (សំបូរព្រៃគុក), ផ្តែរវត្តតាំងក្រសាំង (កំពង់ចាម)។ លោក Victorio Roveda ក៏បានរៀបរាប់ខ្លះៗដែរនៅក្នុងសៀវភៅដ៏ល្បីល្បាញ របស់លោកមានចំណងជើងថា *“Image of the gods”* ។[២] ក្រៅពីនេះ លោក គិម សានពិសិដ្ឋ ក៏ធ្លាប់បានសិក្សាឡើងវិញនៅក្នុងឆ្នាំ ២០០៦ ហើយលោកបានរៀបរាប់ផ្តែរទ្វារមានចម្លាក់ ព្រះវិស្ណុផ្ទុំនៅស.វ.ទី៧ ចំនួន៦ ផ្ទាំង (ផ្តែរទ្វារតាំងនៅសហរដ្ឋអាមេរិច, ផ្តែរទ្វារ ប្រាសាទ បាសែត, ផ្តែរទ្វារនៅទួលអង្គ, ផ្តែរទ្វារវត្តតាំងក្រសាំង, ផ្តែរទ្វារប្រាសាទហាន់ជ័យ និងផ្តែរទ្វារមិនស្គាល់ប្រភពនៅសារមន្ទីរជាតិភ្នំពេញ)។

រឿងទេវកថាព្រះវិស្ណុផ្ទុំមានរៀបរាប់នៅក្នុងគម្ពីរ Viṣṇu-Purāṇa ដែលមានសេចក្តីសង្ខេបដូចតទៅ៖ “នៅពេលលោកទាំងមូលអាប់អួរ ប្រផ្នូលអាក្រក់បានកើតឡើងភាពរាំងស្ងួតកើតឡើងអស់ ១០០ ឆ្នាំ មនុស្សពោរពេញដោយចិត្តលោភៈ ទោសៈ មោហៈ កំណាច ឫស្យា លូងខ្លៅ គ្មានអរហន្ត។ មនុស្សចាស់បាត់បង់សតិបញ្ញាស្មារតីក្លាយទៅជាកូនក្មេងដែលមិនដឹងអី រីឯក្មេងអស់ភាពបរិសុទ្ធ អសីលធម៌ គ្រូអាចារ្យ ក្សត្រ ពាណិជ្ជករ ទាសាធ្លាក់ទៅក្នុងភាពថោកទាប មនុស្សល្ងង់មានសន្ទឹកសន្ធាប់គួរឲ្យខ្លើម ពេលនោះ

[១] Bénisti 1965: 91-117

[២] Victorio Roveda 2005: 55-58

ហើយដែលការបំផ្លាញលោកចាស់ក៏ចាប់ផ្ដើមឡើង ហើយអាទិទេព និង មនុស្សត្រូវស្រូបទៅជាព្រហ្ម័នរង់ចាំការបង្កើតលោកថ្មីម្ដងទៀត ដោយសង្ឃឹមថាលោក ទាំងមូលថ្មីនឹងប្រសើរជាងមុនៗ ក្នុងពេលបង្កើតលោកថ្មី លោកទាំងមូលហ៊ុមព័ទ្ធដោយទឹកជំនន់យ៉ាងធំធេង ភ្លើងឆេះកល្បបំផ្លាញជីវិតនិងអ្វីៗនៅលើលោក ហើយពេលនោះហើយដែលព្រះវិស្ណុមកអន្តរាគមន៍ៗ ទ្រង់បានផ្លាស់ប្ដូររូបរាងច្រើនយ៉ាងដែលដំបូងឡើយជាផ្ទៃទឹកសមុទ្រ បន្ទាប់មកក្លាយជាយក្សមួយផ្ទុំនៅលើផ្ទៃទឹក ក្រោយមកក្លាយជាកុមារទេពកំពុងរត់លេងក្រោមដើមឈើ និងចុងក្រោយក្លាយជាសត្វហង្សព្រៃមួយដែលមានសំឡេងពិរោះដូចជាតន្ត្រីៗ ព្រះវិស្ណុបានបំផ្លាញលោកទាំងអស់ ដោយរលាយសត្វ មានជីវិតទាំងព្រះព្រហ្មដែលនៅខ្ពស់ឆ្ងាយនិងធ្លាប់ជាដួងព្រលឹងនៃជីវិតសត្វលោកៗ ទ្រង់បានផ្ដល់ថាមពលដ៏សម្បើមដល់ព្រះអាទិត្យ ដើម្បីបញ្ចេញកំដៅបំផ្លាញជីវិតសត្វលោក លុះដល់ជីវិតរលាយអស់ហើយ ទ្រង់បានប្រែព្រះកាយជាខ្យល់បក់នាំយកអាកាសពីសត្វលោកទាំងអស់ បន្ទាប់មកទៀតទ្រង់ក្លាយជាភ្លើងដ៏សន្ធោសន្ធៅឆេះរំលាយពិភពលោកៗ ចុងក្រោយទៀតទ្រង់ប្រែព្រះកាយជាដុំពពកបង្អុរភ្លៀងដ៏ត្រជាក់និ ងបរិសុទ្ធប្រៀបដូចជាទឹកដោះគោមកពន្លត់អគ្គិភ័យនេះៗ ផែនដីទាំងមូលក៏បានជួបសេចក្ដីសុខជាស្ថាពរៗ ចំណែកឯការបង្កើតលោកថ្មី មានគម្ពីរជាច្រើនរៀបរាប់ខុសៗគ្នា គម្ពីរមួយនៅសម័យវេទដែលគេនិយមបំផុតបាននិទានថា មានស៊ុតចក្រវាឡមាសមួយដែលតំណាងឱ្យភ្លើងអណ្ដែតលើទឹករាប់ពាន់ឆ្នាំ ហើយនៅទីបំផុតស៊ុតនោះក៏ផ្ទុះឡើងមានទម្រង់ជាមនុស្សអមតៈដែលជាព្រលឹងស្រដៀងនឹងព្រហ្ម័ន ហៅថា "បុរុស"ៗ គម្ពីរមួយទៀតនិទានថា ព្រះវិស្ណុជាអ្នកបង្កើតលោក បានផ្ដេកខ្លួនអស់រយៈកាលយ៉ាងយូរលើផ្ទៃទឹកទ្រដោយស្ទឹកពោធិ និងបៀមមេជើងរបស់ទ្រង់ជាសញ្ញានៃអមតៈ ហើយចុងក្រោយចក្រវាឡទាំងមូលក៏កើតឡើងដោយសារឆន្ទៈរបស់ទ្រង់ ពាក្យសម្ដីនិងសំឡេងកើតឡើងពីមាត់របស់ទ្រង់គម្ពីរវេទកើតចេញពីភាពសប្បាយរីករាយនៃកាយរបស់ទ្រង់ ទឹកទម្រឹតកើតចេញពីអណ្ដាតទ្រង់ ផ្ទៃមេឃកើតចេញពីច្រមុះទ្រង់ ស្ថានសួគ៌និងព្រះអាទិត្យកើតចេញពីព្រះនេត្រទ្រង់ ទឹកទន្លេដែលអាចធ្វើដំណើរកើតចេញពីត្រចៀក ពពកនិងភ្លៀងចេញពីព្រះកេសា ផ្ទេកបន្ទោរចេញពីពុកចង្កា ឬកើតចេញពីក្រចកជើង និងភ្នំកើតចេញពីឆ្អឹងរបស់ទ្រង់ៗ គម្ពីរមួយទៀត

អត្ថបទដោយ៖ លោក ម៉ង់ រ៉ាលី

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

ដែលខ្មែរនិយមត្រាប់តាមឈ្មោះថា "Mārkaṇḍeya-Purāṇa" និទានថាព្រះវិស្ណុបានផ្ទុំនៅលើនាគអនន្តមានក្បាលសេស ដែលជាពេលចុងក្រោយនៃកល្ប ពិភពលោកក៏ប្រែក្លាយទៅជាមហាសមុទ្រ ពេលនោះព្រះព្រហ្មក៏លេចចេញពីផ្ចិតព្រះវិស្ណុទ្រដោយផ្កាឈូកដើម្បីដើរតួនាទីជាអ្នកបង្កើតលោកថ្មី[៣]

ដូចដែលបានលើកខាងលើថា នៅក្នុងអត្ថបទនេះ ខ្ញុំលើកយកមកសង្ខេបតែចម្លាក់ព្រះវិស្ណុផ្ទុំនៅសម័យមុនអង្គរមកបរិយាយប៉ុណ្ណោះ។ ក្នុងនោះ ផ្តែរទ្វារនៅសម័យមុនអង្គរ ស.វ.ទី៧ ចំនួន៨ផ្ទាំងដែលមានចម្លាក់ព្រះវិស្ណុផ្ទុំរួមមាន៖ នៅសំបូរព្រៃគុក១ផ្ទាំង, ភ្នំហាន់ជ័យ១ផ្ទាំង, វត្តតាំងក្រសាំង (កំពង់ចាម) ១ផ្ទាំង, ទួលអង្គ (កំពង់ស្ពឺ) ១ផ្ទាំង, ប្រាសាទបាសែត១ផ្ទាំង, ផ្តែរមិនស្គាល់ប្រភពនៅសារមន្ទីរជាតិភ្នំពេញ១ផ្ទាំង, ផ្តែរមិនស្គាល់ប្រភពនៅសហរដ្ឋអាមេរិច១ផ្ទាំង និងផ្តែរទ្វារយកមកពីស្រុកអូររាំងឪ១ផ្ទាំង។ ក្នុងចំណោមផ្តែរទ្វារទាំង៨នេះ មានតែផ្តែរទ្វារមានរូបព្រះវិស្ណុផ្ទុំយកមកពីស្រុកអូររាំងឪមួយផ្ទាំងប៉ុណ្ណោះដែលមិនធ្លាប់មានសិក្សាពីមុនមក។

ក្នុងចំណោមផ្តែរទ្វារទាំងអស់នេះ យើងឃើញថា ផ្តែរទ្វារដែលរក្សាទុកនៅសហរដ្ឋអាមេរិក មើលទៅហាក់មានភាពចំណាស់ជាងគេ ពោល គឺអាចស្ថិតនៅចុងរចនាបថសំបូរព្រៃគុក ឬដើមរចនាបថព្រៃក្មេង (ស.វ.ទី៧) ហើយផ្តែរផ្សេងៗទៀតស្ថិតនៅក្នុងរចនាបថព្រៃក្មេងស.វ.ទី៧ ដូចៗគ្នា។ ចម្លាក់ព្រះវិស្ណុផ្ទុំនៅលើផ្តែរទ្វារទាំងប្រាំបីនេះ មានទម្រង់ប្លែកៗពីគ្នាខ្លះៗទៅតាមការនិយមរបស់សិល្បករ ឬធ្វើតម្រូវតាមគម្ពីរដែលគេនិយម។ ផ្តែរទី១ រក្សាទុកនៅសារមន្ទីរសហរដ្ឋអាមេរិក យើងឃើញចុងសងខាងផ្តែរឆ្លាក់រូបសត្វមករ រីឯចម្លាក់ព្រះវិស្ណុផ្ទុំ ដោយច្រត់ព្រះហស្តម្ខាងក្រោមព្រះសិរ ព្រះហស្តម្ខាងទៀតចាប់កាន់ដើមឈូកដែលដុះចេញពីផ្ចិតរបស់ទ្រង់ ជារូបព្រះព្រហ្មទ្រដោយផ្កាឈូក នាគនៅខាងក្រោយមានក្បាល៧ ក្បែរព្រះកាយទ្រង់គេឆ្លាក់ ជាទឹករលក និងរំលេចដោយក្បាលសត្វក្រពើដែលតំណាងឱ្យទឹកសមុទ្រ ក្រៅពីនេះនៅសងខាងព្រះព្រហ្មគឺជា មធុ និងកៃដភដែលជាអសុរពីរអង្គដែលចង់សម្លាប់ព្រះព្រហ្ម ដោយគេឆ្លាក់ក្នុងកាយវិការកាន់អាវុធបម្រុងវាយសំដៅមកព្រះព្រហ្ម ហើយគម្ពីរខ្លះសរសេរថា អសុរទាំងពីរ គឺជាអ្នកដែលលួច

---

[៣] Wilson 2005: 18

អត្ថបទដោយ៖ លោក ម៉ង់ វ៉ាលី

យកគម្ពីរវេទពី ព្រះព្រហ្ម(រូបលេខ១)។ ផ្តែរទី២ នៅភ្នំហាន់ជ័យវិញ គេឆ្លាក់ព្រះវិស្ណុផ្ទុំជាចម្លាក់តូចៗចំនួនពីរអង្គដែលលោកស្រី Bénisti យល់ថា ជាការឆ្លាក់បែងចែកសាច់រឿងធំៗពីរដាច់ពីគ្នា ពោល គឺទី១ ព្រះវិស្ណុផ្ទុំចន្លោះពេលបង្កើតលោក (កល្ប) និងទី២ទាក់ទងនឹងកំណើតព្រះព្រហ្មដែលជាទេពបង្កើតលោកថ្មី(រូបលេខ២)។ ផ្តែរទី៣ រកឃើញនៅទួលអង្គ ខេត្តកំពង់ស្ពឺ ដោយសព្វថ្ងៃរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ សិល្បករឆ្លាក់ព្រះវិស្ណុមានព្រះហស្តបួនផ្ទុំលើនាគអនន្តក្បាលប្រាំពីរមានរាងមូលដូចជាផ្ចិត ព្រះហស្តម្ខាងចាប់កាន់ដើមឈូកដែលដុះចេញផ្ចិតចេញជាព្រះព្រហ្មឡើងនៅខាងលើ និងខាងក្រោម ព្រះកាយទ្រង់គេឆ្លាក់ជាក្បាច់ទឹករលកឡើងដែលតំណាងឱ្យមហាសមុទ្រ។ ចម្លាក់ នេះលោកស្រី Bénisti យល់ថាអាចគេត្រាប់តាមគម្ពីរ Bhāgavata-Purāṇa ដែលបង្ហាញពី យុគធំៗពីរ គឺទី១ នៅពេលទ្រង់កំពុងផ្ទុំស្តេចពស់ (នាគអនន្ត) រកឃើញសេចក្តីស្លាប់ក្នុងពេលលោកទាំងមូលកំពុងជន់លិច និងទី២ ពេលដើមឈូកដុះចេញពីផ្ចិតព្រះវិស្ណុលេច ចេញជាព្រះព្រហ្មឡើង (រូបលេខ៣)។[៤] ផ្តែរទី៤ មកនៅវត្តតាំងក្រសាំង (រូបលេខ៤) មានទម្រង់ដូចផ្តែរទី១ ដោយមានចម្លាក់អសុរពីរអង្គ គឺមធុ និងកៃដភកាន់អាវុធបម្រុងសម្លាប់ព្រះព្រហ្ម។ ផ្តែរទី៦ រកឃើញថ្មីដែលស្ថិតនៅស្រុកអូររាំងឪ (រូបលេខ៥) និងផ្តែរមិនស្គាល់ប្រភពនៅសារមន្ទីរជាតិភ្នំពេញមានទម្រង់ដូចគ្នា ប៉ុន្តែមានទម្រង់ខុសពីផ្តែរទី១ និងទី៤ ត្រង់ថាចម្លាក់អសុរទាំងពីរ គឺមធុ និងកៃដភ ពុំមានកាន់អាវុធដូចផ្តែរខាងលើទេ តែសិល្បករឆ្លាក់បង្ហាញ អសុរទាំង ពីរកាន់គម្ពីរវេទដែលបានលួចពីព្រះព្រហ្ម។ ផ្តែរទី៧ នៅប្រាសាទបាសែតដែលសព្វថ្ងៃរក្សាទុកនៅសារមន្ទីរខេត្តបាត់ដំបង (រូបលេខ៦) មានទម្រង់ខុសគ្នាខ្លះពីចម្លាក់ខាងលើ។ ដោយសិល្បករឆ្លាក់ព្រះវិស្ណុផ្ទុំលើនាគក្បាលប្រាំពីរ ក្នុងទម្រង់មានព្រះហស្តបួនព្រះហស្តមួយដាក់សណ្តូកត្រង់ទៅលើ ម្ខាងទៀតច្រត់ព្រះសិរ ពីរទៀតដាក់សណ្តូកត្រង់ទៅក្រោមដោយមិនចាប់កាន់ដើមឈូកដូចចម្លាក់ខាងលើដែលបានរៀបរាប់ទេ។ រីឯនៅសងខាងមានទេពប្រណម្យពីរ និងខាងលើជាព្រះព្រហ្មគង់នៅលើក្បាច់ត្របកផ្កាឈូកមិន មានឆ្លាក់អសុរនៅក្បែរឡើយ។ ចំពោះផ្តែរទី៨ចុងក្រោយ គឺចម្លាក់ព្រះវិស្ណុផ្ទុំរកឃើញនៅសំបូរព្រៃគុក មានទម្រង់ខុសគ្នាពីផ្តែរចំនួន៧ខាងលើ។ សិល្បករឆ្លាក់ព្រះវិស្ណុផ្ទុំលើនាគក្បាលប្រាំពីរមាន

---

[៤] Bénisti, 1965: 92

ពុកមាត់ក្រាស់ ច្រមុះរាបសំប៉ែត ចិញ្ចើមក្រាស់ ពាក់ខ្សែក ខ្សែដៃ ក្រវិលធំ សំពត់ខ្លី ពោលគឺក្នុងទម្រង់ដូចជាយក្សធំមួយដែលត្រាប់តាមគម្ពីរ Visnu Purāna ហើយប្លែកពីផ្តែរផ្សេងនោះ គឺនៅខាងចុងមានចម្លាក់ព្រះនាងលក្ស្មីនៅខាងចុងព្រះបាទព្រះវិស្ណុ។ ចម្លាក់ព្រះនាងលក្ស្មីនៅខាងចុងបែបនេះ គេនិយមខ្លាំងនៅសម័យអង្គរ (រូបលេខ៧)។

ឯកសារយោង៖


Bénisti.

1965. *Représentations khmères de Viṣṇu couché, Arts Asiatiques, Tome 11 fascicule 1*, p. 91-117

Victorio Roveda.

2005. *"Image of the gods"*, pages 55-58

Wilson.

2005. *Visnu Purana Book 1*, Chapter 3, p.18.




រូបលេខ១៖ ផ្តែរទ្វារមិនស្គាល់ប្រភពរក្សាទុកសហរដ្ឋអាមេរិក

(ដកស្រង់ចេញពីសៀវភៅ Adoration and Glory, The Golden Age of Khmer Art, Emma C. Bunker & Douglas)

អត្ថបទដោយ៖ លោក ម៉ង់ រ៉ាលី



រូបលេខ២៖ ផ្តែរទ្វារនៅប្រាសាទគុកព្រះធាតុ (ភ្នំហាន់ជ័យ)



រូបទី៣៖ ផ្តែរទ្វារនៅទួលអង្គ (កំពង់ស្ពឺ)



រូបលេខ៤៖ ផ្តែរទ្វារនៅវត្តតាំងក្រសាំង
ស្រុកបាធាយ ខេត្តកំពង់ចាម

អត្ថបទដោយ៖ លោក ម៉ង់ វ៉ាលី



រូបទី៥៖ ផ្តែរទ្វាររកឃើញនៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ



រូបទី៦៖ ផ្តែរទ្វាររកឃើញនៅប្រាសាទបាសែត ខេត្តបាត់ដំបង



រូបលេខ៧៖ ផ្តែរទ្វាររកឃើញនៅតំបន់ប្រាសាទសំបូរព្រៃគុក

(ដកស្រង់ពីសៀវភៅលោកស្រី Mireille Benisti, 1974)

អត្ថបទដោយ៖ លោក ម៉ង់ វ៉ាលី